# BACCALAURÉATS GÉNÉRAL ET TECHNOLOGIQUE

**SESSION 2019**

# CAMBODGIEN

Mercredi 27 mars 2019

**Épreuve facultative**

Toutes séries sauf **STD2A, STI2D, STL, STMG et ST2S**

Durée de l'épreuve : **2 heures**

**Le candidat traitera, dans la langue étrangère, l'ensemble des questions pour laquelle il compose.**

*L'usage des calculatrices et des dictionnaires est interdit.*

Dès que ce sujet vous est remis, assurez-vous qu'il est complet.
Ce sujet comporte 4 pages numérotées de 1/4 à 4/4.

សន្និសីទអន្តរជាតិស្តីពីអាកាសធាតុលើកទី ២៤ (កុប ២៤) ត្រូវចាប់ផ្តើមបើកទ្វារ ចាប់ពីថ្ងៃអាទិត្យនេះ រហូតដល់ថ្ងៃទី ១៤ ធ្នូ នៅប្រទេសប៉ូឡូញ ។ នៅពេលដែលអ្នកជំនាញខាងអាកាសធាតុ បានព្រមានពីការកើនឡើងនៃកំដៅផែនដី ៣ អង្សាបន្ថែមទៀតពីពេលនេះរហូតដល់ចុងសតវត្សរ៍ ប្រទេសអ្នកមាន ហាក់និយាយចុងមាត់ចុងក ក្នុងរឿងគោរពកិច្ចសន្យា ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលជាប្រភពធ្វើឲ្យផែនដីឡើងកំដៅ ។ ប្រទេសក្រីក្រឯណោះវិញ រង់ចាំជាមួយក្តីសង្ឃឹមតិចតួច ជំនួយបែកពីក្រុមប្រទេសមហាឧស្សាហកម្ម ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ច្រើនរហូតមក ។

គេឃើញយ៉ាងច្បាស់ ជំហរដកក្រោយរបស់ប្រទេសឧស្សាហកម្ម នៅក្នុងការគោរពអនុវត្តធ្វើតាមកិច្ចព្រមព្រៀងស្តីពីអាកាសធាតុ ក្រុងប៉ារីស ។ នៅថ្ងៃម្សិលមិញ នៅក្នុងសេចក្តីថ្លែងការណ៍នៅក្រោយកិច្ចប្រជុំ ហ្សេ ២០ នៅប្រទេសអាហ្សង់ទីន សមាជិករបស់ក្រុមប្រទេសមហាអំណាចឧស្សាហកម្មទាំង ២០ ដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀង ស្តីពីអាកាសធាតុ (លើកលែងតែអាមេរិក ដែលដកខ្លួនចេញ កាលពីឆ្នាំ ២០១៧) បានត្រឹមតែបញ្ជាក់ថា គេនឹងចូលរួមអនុវត្តធ្វើតាមកិច្ចព្រមព្រៀង ប៉ុន្តែ មិនបានលម្អិតអ្វីច្រើននោះទេ ។

នៅក្នុងសន្និសីទរបស់អង្គការសហប្រជាជាតិ រយៈពេល ១២ ថ្ងៃ ដែលចាប់ផ្តើមបើកធ្វើនៅថ្ងៃអាទិត្យនេះ នៅប្រទេសប៉ូឡូញ ប្រទេសចំនួន ២០០ នៅក្នុងពិភពលោក ត្រូវពិភាក្សា ដើម្បីដាក់ឲ្យអនុវត្តកិច្ចព្រមព្រៀងក្រុងប៉ារីស ដែលសំដៅទប់ទល់កុំឲ្យកំដៅលើផែនដី កើនឡើង ២ អង្សាបន្ថែមទៀតពីពេលនេះរហូតដល់ចុងសតវត្សរ៍ទី ២១ ។ ជារួម គេត្រូវផលិតឲ្យបានសៀវភៅបទបញ្ជាមួយ ដែលមានចែងតាំងពីតម្លាភាព បរិមាណឧស្ម័នកាបូនិក ដែលគេត្រូវកាត់បន្ថយ ហើយនិងថវិកាសម្រាប់ជួយប្រទេសក្រីក្រ ដែលរងផលប៉ះពាល់រួចហើយ ដោយសារការប្រែប្រួលអាកាសធាតុ ។

បញ្ហាថវិកា ហើយនិងការចូលរួមកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ជាសំណួរចោទចំបង ដែលគេគេចវេះមិនចង់លើកនិយាយ ។ ទៅតាមកិច្ចព្រមព្រៀងស្តីពីអាកាសធាតុ ក្រុងប៉ារីស ក្រុមប្រទេសអ្នកមាន បានសន្យាផ្តល់វិភាគទានដល់កញ្ចប់ថវិកាបៃតង ដែលត្រូវមាន ១០០ ពាន់លានដុល្លារក្នុងមួយឆ្នាំ ៗ រហូតដល់ឆ្នាំ ២០២០ ។ ប៉ុន្តែ តាមរបាយការណ៍របស់អង្គការអុក្សហ្វាំ មានតែថវិកាតែពាក់កណ្តាលតែប៉ុណ្ណោះ ដែលត្រូវបានគេផ្តល់សម្រាប់ជំនួយកញ្ចប់បៃតង ។ ក្រុមប្រទេសអ្នកមាន ប្រទេសមហាឧស្សាហកម្ម វាយតម្លៃថា ថវិកាបៃតង គឺសម្រាប់ជួយទ្រទ្រង់សកម្មភាពគម្រោងការវិនិយោគណាដែលជួយកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិក ប៉ុន្តែ សម្រាប់ប្រទេសក្រីក្រ ពួកគេស័ក្តិសមនឹងទទួលបានជំនួយ ដោយសារតែជីវិតរស់នៅរបស់ពួកគេ ត្រូវបានប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ ឬការបញ្ចេញឧស្ម័នកាបូនិករបស់ក្រុមប្រទេសអ្នកមាន ។

នៅពេលដែលក្រុមប្រទេសអ្នកក្រ និងក្រុមប្រទេសមហាឧស្សាហកម្ម យល់មិនដូចគ្នា គេឃើញកើតមានផងដែរ ការខ្វែងគំនិតគ្នារវាងក្រុមប្រទេសមហាឧស្សាហកម្ម ក្នុងរឿងកាត់បន្ថយឧស្ម័នកាបូនិក ឧស្ម័នផ្ទះកញ្ចក់ ដែលជាប្រភពធ្វើឲ្យផែនដីឡើងកំដៅ ។ ប្រទេសមួយចំនួន បានបដិសេធ មិនផ្លាស់ប្តូរប្រភពថាមពលរបស់ខ្លួន ដើម្បីហេតុផលប្រយោជន៍សេដ្ឋកិច្ច ។ ជាក់ស្តែង ប៉ូឡូញ ដែលធ្វើជាប្រទេសម្ចាស់ផ្ទះរៀបចំសន្និសីទស្តីពីអាកាសធាតុលើកនេះ នៅតែការពារនយោបាយប្រើប្រាស់ធ្យូងថ្ម ដើម្បីផលិតថាមពលក្នុងស្រុក ទោះបើទោះបីជាធ្យូងថ្មបញ្ចេញឧស្ម័នកាបូនិកច្រើនជាងគេក៏ដោយ ។ នៅប្រេស៊ីល ជាទីដែលមានការកាប់បំផ្លាញព្រៃអាម៉ាហ្សូនក្នុងទ្រង់ទ្រាយធំមិនធ្លាប់មាន ប្រធានាធិបតីថ្មីរបស់ប្រេស៊ីល ដែលកោតសរសើរនយោបាយរបស់ប្រធានាធិបតី ដូណាល់ ត្រាំ បានប្រកាសបដិសេធមិនទទួលរៀបចំសន្និសីទស្តីពីអាកាសធាតុលើកទី ២៥ ដែលត្រូវគ្រោងធ្វើនៅឆ្នាំក្រោយ ។

« ការប្រែប្រួលអាកាសធាតុ » នៅពេលប្រទេសមហាឧស្សាហកម្មធ្វើ ហាក់ចង់ដោះដៃ ដូចអាមេរិក » ដោយ លាង ពុទ្ធា, វិទ្យុបារាំងអន្តរជាតិ ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០១៨ (http://km.rfi.fr/europe/20181202-division-even-before-Cop24-start-in-poland) ។

## Vocabulaire - វាក្យសព្ទ

- ការវិនិយោគ : investissement
- កសិកម្ម : agriculture : agricole
- កិច្ចព្រមព្រៀង : accords
- កិច្ចសន្យា : contrat
- កុប ២៤ : COP24 (24e conférence annuelle de la Convention-cadre des Nations unies sur les changement climatiques)
- គម្រោង : projet
- គ្រោង : projeter, prévoir
- ចែង : énoncer, stipuler
- ជំហរ : posture, position
- តម្លាភាព : transparence
- ថវិកា : budget
- ថាមពល : énergie
- ទិន្នផល : rendement(s)
- ធ្យូងថ្ម : houille, minerai de charbon
- នយោបាយ : politique
- បទបញ្ញា : règlement, règlementation
- បរិមាណ : quantité
- ប្រកាស : déclarer
- ប្រភព : source
- ផលប៉ះពាល់ : effet(s)
- ផលិត : produire
- ផ្ទះកញ្ចក់ : serre
- ព្រមាន : avertir
- មហាអំណាច : grande puissance
- របាយការណ៍ : rapport
- វិភាគទាន : contribution
- សកម្មភាព : activité
- សតវត្សរ៍ : siècle
- សន្និសីទ : conférence
- សមាជិក : membre
- ហត្ថលេខី : signataire
- ហ្សេ ២០ : G20
- អង្គការ : organisation
- អង្គការសហប្រជាជាតិ : Organisation des Nations unies
- អង្សា : degré
- អនុវត្ត : appliquer
- អន្តរជាតិ : international
- អាកាសធាតុ : climat : climatique
- អុក្សហ្វាំ : Oxfam (Oxford Committee for Famine Relief)
- អ្នកជំនាញ : expert
- ឧស្ម័ន : gaz
- ឧស្ម័នផ្ទះកញ្ចក់ : gaz à effet de serre
- ឧស្សាហកម្ម : industrie

## QUESTIONS

### I. COMPRÉHENSION DE L'ÉCRIT : (10 points)

១-ក. តើសន្និសីទអ្វីដែលបើកទ្វារនៅប្រទេសប៉ូឡូញ ហើយធ្វើឡើងពីថ្ងៃណាដល់ថ្ងៃណា? (១ ពិន្ទុ)

១-ខ. តើកិច្ចប្រជុំរបស់ ហ្សេ ២០ (ក្រុមមហាអំណាចឧស្សាហកម្ម ២០ ប្រទេស) បានធ្វើឡើងនៅប្រទេសណា? (១ ពិន្ទុ)

១-គ. តើប្រទេសចំនួន ២០០ ក្នុងពិភពលោក នឹងពិភាក្សាពីរឿងអ្វី? (២ ពិន្ទុ)

១-ឃ. តើហេតុអ្វីបានជាប្រទេសខ្លះបដិសេធមិនផ្លាស់ប្តូរប្រភពថាមពល? (១ ពិន្ទុ)

**Traduction – ការបកប្រែ** (៥ ពិន្ទុ)

១-ង. ចូរបកប្រែអត្ថបទចាប់ពីបន្ទាត់ទី ១២ «នៅក្នុងសន្និសីទរបស់អង្គការសហប្រជាជាតិ ...» ដល់បន្ទាត់ទី ១៧ «... ដោយសារការប្រែប្រួលអាកាសធាតុ ។» ។

### II. EXPRESSION ÉCRITE : (10 points)

**Afin de respecter l'anonymat de votre copie, vous ne devez pas signer votre composition, citer votre nom, celui d'un camarade ou celui de votre établissement.**

Le candidat traite <u>UNE</u> question au choix (150 mots minimum).

២-ក. តើអ្នកធ្លាប់បានគិតឬទេ អំពីអនាគតរបស់ផែនដី ការបំពុលទឹក ការបំពុលខ្យល់ និងការបំពុលដី ជាដើម? តើអ្នកផ្ទាល់ នឹងធ្វើអ្វីខ្លះចំពោះបញ្ហាទាំងនេះ? ចូររៀបរាប់ឲ្យបានក្បោះក្បាយ ។

២-ខ. យើងទាំងអស់គ្នា ស្ថិតនៅក្នុងភាពអាសន្ន ។ កំដៅផែនដី មានផលប៉ះពាល់ដ៏ធ្ងន់ធ្ងរខ្លាំងក្លាឲ្យចមកហើយ (មហាព្យុះ ការរាំងស្ងួត ឬ ជំនន់ ការថយចុះនៃទិន្នផលកសិកម្ម) ដោយមានភាពផ្ទួន ៗ ដែលពុំឃើញមានពីមុនមក ។ តែស្របពេលជាមួយគ្នានេះ ក្នុងប្រទេសខ្លះ ប្រជាពលរដ្ឋបានបោះឆ្នោតទាំងដឹងខ្លួន ឲ្យប្រធានាធិបតី ដែលបដិសេធ មិនទទួលស្គាល់ការប្រែប្រួលអាកាសធាតុ (ដូចជា លោក ដូណាល់ ត្រាំ នៅសហរដ្ឋអាមេរិក ឬ លោក យ៉ាអៀរ បុលសូណារ៉ូ នៅប្រេស៊ីល) ឬដែលនិយាយថា ត្រូវគិតពីសេដ្ឋកិច្ចជាតិសិន ពោលគឺ ជាគោលនយោបាយគិតខ្លី មិនគិតវែងឆ្ងាយទេ ។ តាមយោបល់អ្នក តើគួរធ្វើអ្វីខ្លះ? ចូររៀបរាប់ឲ្យបានក្បោះក្បាយ ។